ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិសន្តិសុខសង្គម

លេខ :....០១៥/២៦....ប.ស.ស.

# សេចក្តីណែនាំ
## ស្តីពី
## ការប្រើប្រាស់និមិត្តសញ្ញាសម្គាល់ និងឈ្មោះរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)

បេឡាជាតិសន្តិសុខសង្គម (**ប.ស.ស.**) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្កេតឃើញថា កន្លងមក មានរូបវន្តបុគ្គល ឬនីតិបុគ្គល មួយចំនួនដែលមិនមែនជាដៃគូសហការតាមរយៈកិច្ចព្រមព្រៀងណាមួយជាមួយ **ប.ស.ស.** បានយកនិមិត្តសញ្ញាសម្គាល់ (Logo) របស់បេឡាជាតិសន្តិសុខសង្គម ឬឈ្មោះ **ប.ស.ស.** ឬរូបប័ណ្ណសមាជិក **ប.ស.ស.** ទៅប្រើប្រាស់ក្នុងគោលដៅកេងចំណេញផលប្រយោជន៍ ឬប្រើប្រាស់ក្នុងចេតនាទុច្ចរិត តាមរយៈការដាក់តាំងបង្ហាញនៅតាមទីសាធារណៈ ក្នុងទម្រង់ជា បដា ឯកសារផ្សព្វផ្សាយពាណិជ្ជកម្ម និងឯកសាររដ្ឋបាលផ្សេងៗ ព្រមទាំងប្រើជារូបសញ្ញា (Profile) នៅលើបណ្តាញសង្គម ឬកម្មវិធីទំនាក់ទំនងសង្គមផ្សេងៗ ដោយមិនបានស្នើសុំការអនុញ្ញាតជាមុនពី **ប.ស.ស.** ដែលសកម្មភាពទាំងនេះធ្វើឱ្យមានការយល់ច្រឡំ និងប៉ះពាល់ដល់ជំនឿទុកចិត្តលើ **ប.ស.ស.** ពីសាធារណជន និងសមាជិក **ប.ស.ស.** ដូច្នេះ បេឡាជាតិសន្តិសុខសង្គម (**ប.ស.ស.**) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមធ្វើការណែនាំដូចខាងក្រោម៖

១. រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនមែនជាដៃគូសហការតាមរយៈកិច្ចព្រមព្រៀងណាមួយជាមួយ **ប.ស.ស.** បាននិងកំពុងប្រើប្រាស់និមិត្តសញ្ញាសម្គាល់ ឬឈ្មោះ **ប.ស.ស.** គ្រប់រូបភាព និងគ្រប់ទម្រង់ក្នុងគោលដៅកេងចំណេញផលប្រយោជន៍ ឬប្រើប្រាស់ក្នុងចេតនាទុច្ចរិត ត្រូវបញ្ឈប់ ដកចេញ ឬលុបចេញជាបន្ទាន់។ ករណីរូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលនៅតែបន្តសកម្មភាពនេះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

២. រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងប្រើប្រាស់និមិត្តសញ្ញាសម្គាល់ ឬឈ្មោះ **ប.ស.ស.** តាមទីសាធារណៈទោះក្នុងទម្រង់ណាមួយក៏ដោយ ត្រូវស្នើសុំការអនុញ្ញាតជាមុនពី **ប.ស.ស.** តាមរយៈទូរសព្ទលេខ ០២៣ ៩៩៩ ២១៩ / ០១១ ៦៧៦ ៦០៦។

៣. ការហាមឃាត់នេះ មិនត្រូវបានអនុវត្តចំពោះការយកព័ត៌មានទៅចែកចាយក្នុងន័យអប់រំ ផ្តល់ចំណេះដឹង ឬការរាយការណ៍ព័ត៌មាន ដែលមានប្រភពត្រឹមត្រូវនោះទេ ដរាបណាការបង្ហាញនោះមិនមានចេតនាបន្លំខ្លួនជាមន្ត្រី ឬតំណាងផ្លូវការរបស់ **ប.ស.ស.** ឬមិនប៉ះពាល់ដល់ស្ថាប័ន **ប.ស.ស.**។

បេឡាជាតិសន្តិសុខសង្គម សូមលើកទឹកចិត្តដល់អង្គភាពសាធារណៈ ឬឯកជន អង្គភាពសារព័ត៌មាន ឬអ្នកមានប្រជាប្រិយភាព ឬអ្នកផលិតមាតិកា ឬសមាជិក **ប.ស.ស.** ក្នុងការជួយផ្សព្វផ្សាយចំណេះដឹងស្តីពីរបបសន្តិសុខសង្គម។ ក្នុងករណីមានតម្រូវការប្រើប្រាស់និមិត្តសញ្ញាសម្គាល់ដែលមានគុណភាពខ្ពស់ និងត្រឹមត្រូវ



ទីស្នាក់ការកណ្តាល បេឡាជាតិសន្តិសុខសង្គម
ភូមិសំរោង សង្កាត់ឃ្មួញ
ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ : (៨៥៥) ២៣ ២៦ ០០ ០១ / (៨៥៥) ២៣ ៩៩ ៩២ ១៩
ទូរស័ព្ទ Hotline : ១២៨៦
លេខកូដតំបន់ : ១២០៨០៣
ទំព័រហ្វេសបុក : www.facebook.com/nssfpage
តេឡេក្រាម : t.me/nssfcambodia
គេហទំព័រ : www.nssf.gov.kh

តាមបច្ចេកទេស លោកអ្នកអាចទាញយក **សៀវភៅមគ្គុទ្ទេសក៍ប្រើប្រាស់និមិត្តសញ្ញាសម្គាល់របស់បេឡាជាតិសន្តិសុខសង្គម និងនិមិត្តសញ្ញាសម្គាល់** តាមរយៈ **QR Code** ខាងក្រោម។

បេឡាជាតិសន្តិសុខសង្គម (**ប.ស.ស.**) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា រូបវន្តបុគ្គល នីតិបុគ្គល និងសាធារណជនទាំងអស់ ចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ២០២៦

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**

**អគ្គនាយកបេឡាជាតិសន្តិសុខសង្គម**

**ម៉េង ហុង**

សូមទាញយកសៀវភៅមគ្គុទ្ទេសក៍
និងនិមិត្តសញ្ញាសម្គាល់
តាមរយៈ QR Code ខាងក្រោម៖

**កន្លែងទទួល៖**

- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស.
- ឯកសារ កាលប្បវត្តិ